ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មូលនិធិគន្ធបុប្ផាកម្ពុជា

លេខ :................ម.គ.ក........

*ថ្ងៃ ចន្ទ ០២ កើត ខែ អស្សុជ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣*

*រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០១៩*

# សេចក្ដីប្រកាសព័ត៌មាន

## ស្ដីពីពិធីប្រគល់-ទទួលថវិកាបរិច្ចាគជូនមូលនិធិគន្ធបុប្ផាកម្ពុជា រវាងឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី និង លោក Qiu Guoxing ប្រធានប្រតិបត្តិក្រុមហ៊ុន Prince Real Estate (Cambodia) Group Co.,Ltd និងជាប្រធានសមាគមមិត្តភាព សភាពាណិជ្ជកម្មចិនហ្វូជាននៅកម្ពុជា

នាព្រឹកថ្ងៃចន្ទ ០២ កើត ខែ អស្សុជ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ នៅទីស្ដីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, **ឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** និងជាប្រធានក្រុមប្រឹក្សាភិបាលនៃមូលនិធិគន្ធបុប្ផាកម្ពុជា បានទទួលជួបជាមួយ **លោក Qiu Guoxing** ប្រធានអគ្គនាយកក្រុមហ៊ុន Prince Real Estate (Cambodia) Group Co., Ltd និងជាប្រធានសមាគមមិត្តភាពសភាពាណិជ្ជកម្មចិនហ្វូជាននៅកម្ពុជា និងសហការី ដែលបាននាំមកនូវថវិកាសប្បុរសធម៌ចំនួន ២៣៥, ២៨៥ ដុល្លារអាមេរិក ដើម្បីបរិច្ចាគជូនមូលនិធិគន្ធបុប្ផាកម្ពុជា។

ក្នុងនាមប្រធានក្រុមប្រឹក្សាភិបាលនៃមូលនិធិគន្ធបុប្ផាកម្ពុជា, ឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋ-មន្ត្រី បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងវាយតម្លៃខ្ពស់ចំពោះការចូលរួម និងគាំទ្រជាប្រចាំរបស់ លោក Qiu Guoxing ពិសេសពីសំណាក់ក្រុមហ៊ុន Prince Real Estate (Cambodia) Group Co., Ltd និងសមាគមមិត្តភាពសភាពាណិជ្ជចិនហ្វូជាននៅកម្ពុជា ដែលបានបន្ថែមចំណែកក្នុងសកម្មភាពមនុស្សធម៌នេះ ឆ្លើយតបចំពោះការអំពាវនាវ និងលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជាដែលជាប្រធានស្ថាបនិកមូលនិធិគន្ធបុប្ផាកម្ពុជា។ **ឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានលើកឡើងថាកាយវិការណ៍ដ៏សប្បុរសនេះ គឺការរួមចំណែកក្នុងការលើកកម្ពស់ស្មារតីជួយគ្នាទៅវិញទៅមក ដែលបង្ហាញពីការជួយ និងចូលរួមចំណែកក្នុងការអភិវឌ្ឍនៅកម្ពុជា ក៏ដូចជាការបន្តផ្សារភ្ជាប់ទំនាក់ទំនង និងពង្រឹងមិត្តភាពល្អរវាងប្រទេស និងវិនិយោគិន ក៏ដូចជា រវាងប្រជាជនចិន និងកម្ពុជា ដែលមានទំនាក់ទំនងជិតស្និទ ជាមួយគ្នាជាយូរមកហើយ។

លេខាធិការដ្ឋានមូលនិធិគន្ធបុប្ផាកម្ពុជា
អាសយដ្ឋានៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ទូរស័ព្ទ: ៨៥៥-៦១-៧០១-១១១ / ៨៥៥-៨១-៧០១-១១១១ / ៨៥៥-៩០-៨៨៨-០៧២
Facebook.com/CambodiaKanthaBophaFoundation

ជាការឆ្លើយតប **លោក Qiu Guoxing** ថ្លែងអំណរគុណចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ដែលបានឆ្លៀតពេលដ៏មមាញឹកទទួលលោក និងប្រតិភូនៃក្រុមហ៊ុន Prince Real Estate (Cambodia) Group Co., Ltd និងសមាគមមិត្តភាពសភាពាណិជ្ជចិនហ្វូជាននៅកម្ពុជា និងបានសម្តែងការកោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានបង្កើតមូលនិធិគន្ធបុប្ផាកម្ពុជានេះ ដើម្បីចូលរួមធានានិរន្តរភាពរបស់មន្ទីរពេទ្យគន្ធបុប្ផា។ លោក Qiu Guoxing ក៏បានសម្តែងនូវសេចក្តីសោមនស្សរីករាយ ដែលបានរួមចំណែកក្នុងការគាំទ្រដល់ការគិតគូររបស់រាជរដ្ឋាភិបាលក្នុងការងារមនុស្សធម៌នេះ និងបានសន្យាបន្តបំផុសចលនាគាំទ្រ និងចូលរួមជាមួយមូលនិធិគន្ធបុប្ផាកម្ពុជា។

នៅទីបញ្ចប់នៃជំនួប ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី បានលើកទឹកចិត្តឱ្យក្រុមហ៊ុនខិតខំបន្ត និងពង្រីកការវិនិយោគឱ្យបានកាន់តែទូលំទូលាយ ដើម្បីការអភិវឌ្ឍទាំងក្រុមហ៊ុន និងការអភិវឌ្ឍប្រទេសកម្ពុជា។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានអំពាវនាវ និងបន្តលើកទឹកចិត្តថ្នាក់ដឹកនាំ និងសមាជិកគ្រប់លំដាប់ថ្នាក់នៃក្រុមហ៊ុន Prince Real Estate (Cambodia) Group Co., Ltd និងសមាគមមិត្តភាពសភាពាណិជ្ជចិនហ្វូជាននៅកម្ពុជា ក៏ដូចជាក្រសួង-ស្ថាប័នរដ្ឋ ក្រុមហ៊ុន និងបណ្តាសាធារណជន ឱ្យចូលរួមបរិច្ចាគ និងចូលជាសមាជិក មូលនិធិគន្ធបុប្ផាកម្ពុជា ដើម្បីធានាបាននូវនិរន្តរភាពរបស់មន្ទីរពេទ្យគន្ធបុប្ផាទាំងប្រាំទីតាំង និងដើម្បីភាពញញឹមរបស់កុមារ។ សូមគូសបញ្ជាក់ផងដែរថា កាលពីឆ្នាំ២០១៨ កន្លងមក ក្រុមហ៊ុន Prince Real Estate (Cambodia) Group Co., Ltd បានចូលជាសមាជិកស្ថាបនិកមូលនិធិគន្ធបុប្ផាកម្ពុជា ចំនួន ២៩,២០៨ ដុល្លារអាមេរិក និងសមាគមមិត្តភាពសភាពាណិជ្ជចិនហ្វូជាននៅកម្ពុជា ក៏បានចូលជាសមាជិកស្ថាបនិកមូលនិធិគន្ធបុប្ផាកម្ពុជា ចំនួន ៣០,៦០០ ដុល្លារអាមេរិក ផងដែរ ។